ក N°13/15→19/02/2015

# មាតិកា

## I~ ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៧-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/០៩៨ ស្តីពី ការតម្លើងឋានៈឯកឧត្តម **យី ឆន់** ទីប្រឹក្សាសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ រដ្ឋមន្ត្រី | ១៤៨៧ |
| ០៧-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/០៩៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប | ១៤៨៨ |
| ០៧-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ២៩ រូប | ១៤៨៩ |
| ១០-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៣ ស្តីពី ការតែងតាំង ឯកឧត្តម **ច័ន្ទ មនោ** ជាទីប្រឹក្សា អមក្រសួងយុត្តិធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន | ១៤៩១ |
| ១០-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៤ ស្តីពី ការប្រគល់មុខតំណែង ឯកឧត្តម **ទ្រី សុចរិទ្ធ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ | ១៤៩២ |
| ១០-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៥ ស្តីពី ការប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ ជាករណីពិសេស ដល់មន្ត្រីរាជការ ១១ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៤៩៣ |
| ១០-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៦ ស្តីពី ការដាក់ ឱ្យចូលនិវត្តន៍ ឯកឧត្តម **កែវ សែន** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ របស់ក្រសួងមហាផ្ទៃ | ១៤៩៥ |
| ១០-០២-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់មន្ត្រីរាជការ ០២ រូប ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានឋានៈស្មើ អគ្គនាយក | ១៤៩៦ |

១២-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិកិត្តិយស ដល់មន្ត្រីរាជការ ០៣ រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ១៤៩៧

១២-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១០៩ ស្តីពី ការតែងតាំង ឯកឧត្តម **ហ៊ីង ច័ន្ទម៉ុន្ថា** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១៤៩៨

១២-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១១០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់លោកវរសេនីយ៍ឯក **វណ្ណៈ មង្គល** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៤៩៩

# II. រាជរដ្ឋាភិបាល

## ១. អនុក្រឹត្យ

១៣-០២-២០១៥ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ១៥០០

១៣-០២-២០១៥ -អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ១៥០២

១៦-០២-២០១៥ -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៥០៥

១៩-០១-២០១៥ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៥០៧

១៩-០១-២០១៥ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៥០៨

២៨-០១-២០១៥ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ១៥០៩

២៨-០១-២០១៥ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៥១១

២៨-០១-២០១៥ -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៥១២

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៥១៣

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៥១៤

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ ១៥១៥

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៥១៧

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៥២១

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៥២៥

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៥២៧

២៩-០១-២០១៥ -អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៥២៨

០២-០២-២០១៥ -អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ១៥៣០

០២-០២-២០១៥ -អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់ និងតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ១៥៣៧

០៥-០២-២០១៥ -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ១៥៣៩

០៥-០២-២០១៥ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៥៤៣

០៥-០២-២០១៥ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពី ការផ្លាស់ប្តូរភារកិច្ច និងតែងតាំងប្រធានក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តសៀមរាប អាណត្តិទី ៣ ១៥៤៤

០៥-០២-២០១៥ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពី ការបន្តអាណត្តិមុខតំណែងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៥៤៦

០៦-០២-២០១៥ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៥៤៨

០៦-០២-២០១៥ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ១៥៤៩

០៦-០២-២០១៥ -អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៥៥១

០៦-០២-២០១៥ -អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៥៥២

០៦-០២-២០១៥ -អនុក្រឹត្យលេខ ១១៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៥៥៤

០៦-០២-២០១៥ -អនុក្រឹត្យលេខ ១២០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៥៥៥


## ២~សេចក្តីសម្រេច


០៩-០២-២០១៥ -សេចក្តីសម្រេចលេខ ០៦ សសរ ស្តីពី ការបន្ថែមសមាសភាពនៃគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ១៥៥៧

១៧-០២-២០១៥ -សេចក្តីសម្រេចលេខ ០៨ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យទន្លេ ឆ្នាំ ២០១៥ ចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៥ នៅខេត្តក្រចេះ ១៥៥៩

## III_ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-០១-២០១៥ -ប្រកាសលេខ ១៥១ សហវ.ប្រក ស្ដីពី ការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរ ឥណទានថវិកាជំពូក ៦៤ (ប្រាក់បៀវត្ស) ជូនប្រធានមន្ទីរ ឬអង្គភាព នៅតាមរាជធានី ខេត្ត ១៥៧០

៣០-០១-២០១៥ -ប្រកាសលេខ ១៧៨ សហវ.ប្រក ស្ដីពី គោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្ដល់ ឥណទានដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ១៥៧២

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/០៩៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

## ត្រាស់បង្គាប់

តម្លើងឋានៈឯកឧត្តម **ឃី ធន់** ទីប្រឹក្សា **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

៣៧៧.១៥០២.០៩៩
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០៣/១៥ រ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

[signature]

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ៖

-**ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ** ដល់លោកឧត្តមសេនីយ៍ត្រី **លីវ សុផាណារិទ្ធិ** អត្តលេខ ៥៥៤១៥

-**ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី** ដល់លោកវរសេនីយ៍ឯក **ម៉ា សំណាង** អត្តលេខ ០១២៨៨

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

រាជ. ១៥០២. ១០០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខ: ១២៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | ចៅ យុត្តិបុត្រ | អត្តលេខ | ០១១៥៨៨ |
| ២- | ឧត្តមសេនីយ៍ទោ | ច័ន្ទ ពន្លឺក | អត្តលេខ | ០១៤៤៦២ |
| ៣- | ឧត្តមសេនីយ៍ទោ | ជា សុទ្ធី | អត្តលេខ | ០២២៣១៧ |
| ៤- | ឧត្តមសេនីយ៍ទោ | លី ស៊ុន | អត្តលេខ | ០០៤៤១៥ |
| ៥- | ឧត្តមសេនីយ៍ទោ | ហុង ណារិទ្ធ | អត្តលេខ | ១០៦៩៦២ |
| ៦- | ឧត្តមសេនីយ៍ទោ | ម៉ែន រ៉ា | អត្តលេខ | ០០៤៧៣៣ |
| ៧- | ឧត្តមសេនីយ៍ទោ | ប៊ុន យាង | អត្តលេខ | ០៣២៦៤៧ |
| ៨- | ឯកឧត្តម | ជិន ឈុនឡេង | | |
| ៩- | ឯកឧត្តម | ប៊ុន ស៊ីថា | | |
| ១០- | ឯកឧត្តម | គុណ ញឹម | | |
| ១១- | លោក | សុខ គីមសាន្ត | | |
| ១២- | លោកជំទាវ | ចាន់ សាមី ស្រី ឳក | | |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ត្រី | ព្រហ្ម ជន | អត្តលេខ | ០០៣២២៧ |
| ២- | វរសេនីយ៍ឯក | ផូរ ស៊ីមអ៊ា | អត្តលេខ | ០០៣៣៥៥ |
| ៣- | វរសេនីយ៍ឯក | អឿ វណ្ណៈ | អត្តលេខ | ០២៣៣៤៣ |
| ៤- | វរសេនីយ៍ឯក | សុខ គីមសឿន | អត្តលេខ | ០១៤៧៣៨ |
| ៥- | វរសេនីយ៍ទោ | គិត សុផល | អត្តលេខ | ០៤៣៤២៣ |
| ៦- | វរសេនីយ៍ត្រី | ឈា ច័ន្ទរិទ្ធី | អត្តលេខ | ០០៥២១៩ |
| ៧- | វរសេនីយ៍ត្រី | ស៊ិន ស៊ាន | អត្តលេខ | ០៤២៣២៥ |
| ៨- | លោកស្រី | ពេជ្រ ច័ន្ទស្រីពៅ | | |

**គ-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :**

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | **ម៉ែន សារ៉ាត** | អត្តលេខ | ០០៤៥៨១ |
| ២- | ឧត្តមសេនីយ៍ត្រី | **សែម សារិទ្ធ** | អត្តលេខ | ០២៣៨៦៦ |
| ៣- | ឧត្តមសេនីយ៍ត្រី | **ឈឹម ឆែម** | អត្តលេខ | ០១៤៦០២ |
| ៤- | វរសេនីយ៍ឯក | **ម៉ា ចិត្រា** | អត្តលេខ | ០៥១០៤៤ |
| ៥- | វរសេនីយ៍ឯក | **ជាំ ពុធថាវី** | អត្តលេខ | ០៤៧៩១៧ |
| ៦- | វរសេនីយ៍ឯក | **ហ៊ិន សុខា** | អត្តលេខ | ០២៤៥៥៤ |
| ៧- | វរសេនីយ៍ឯក | **យិន សាន** | អត្តលេខ | ០០៦២៥៧ |
| ៨- | វរសេនីយ៍ត្រី | **យួន សំអុល** | អត្តលេខ | ០១២៤៧២ |
| ៩- | វរសេនីយ៍ត្រី | **ស្រេង ចិន្តា** | អត្តលេខ | ០១៣៧៤០ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស. ១៥០២-១០៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ១៧៣ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **ច័ន្ទ មនោ** ជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ មានឋានៈស្មើរដ្ឋលេខាធិការបន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ១៥៧. ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៨៧. ១៥០២. ១០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ប្រគល់មុខតំណែង ឯកឧត្តម **ទ្រី សុធារិទ្ធ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៨ ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៥០២.០១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខ: ១២៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ ជាករណីពិសេស ដល់មន្ត្រីរាជការ ១១រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :

| | | |
|---|---|---|
| ១- ឯកឧត្តម **អៀង ស៊ុនលី** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២- ឯកឧត្តម **គុណា ញឹម** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣- លោក **ឯមឃិន ថរៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៥ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៤- លោក **ទួន ច័ន្ទរិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥- លោក **ទួន ទិត្យ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៦- លោក **ហ៊ីម គឹមហេង** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៧- លោក **ខង់ ពេជ្រ** ពីនាយក្រមការ ថ្នាក់លេខ ១ មកអនុមន្ត្រី ថ្នាក់លេខ ៣

៨- លោក **អ៊ុង ពន្សបញ្ញា** ពីនាយក្រមការ ថ្នាក់លេខ ១ មកអនុមន្ត្រី ថ្នាក់លេខ ៣

៩- លោកស្រី **ម៉ឺង ដានី** ពីនាយក្រមការ ថ្នាក់លេខ ១ មកអនុមន្ត្រី ថ្នាក់លេខ ៣

១០- លោកស្រី **ស្វាយ ច័ន្ទស៊ីសូផា** ពីនាយក្រមការ ថ្នាក់លេខ ២ មកអនុមន្ត្រី ថ្នាក់លេខ ៥

១១- លោក **តិន សុភក្រ** ពីភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ ១០ មកអនុមន្ត្រី ថ្នាក់លេខ ១៤

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០២១៥.១០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ១២៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ឱ្យចូលនិវត្តន៍ ឯកឧត្តម កែវ សែន ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់របស់ក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៥។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible].១៥០២.១០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: [illegible] ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈដល់មន្ត្រីរាជការ២រូប ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានឋានៈស្មើអគ្គនាយកៈ

១- ឯកឧត្តម **អ៊ុំង សុភារិទ្ធ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងយុត្តិធម៌

២- ឯកឧត្តម **មួន សុមុនី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងយុត្តិធម៌

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល. ១៥០២.១០៧

លេខ: ១២៥ ស.ណ

**សំណៅដែលមានគម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិកិត្តិយស ដល់មន្ត្រីរាជការ ០៣រូប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **អន** | **ស៊ាម** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២- | ឯកឧត្តម | **យី** | **ផង់** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ៣- | ឯកឧត្តម | **សៀម** | **ខ៉ាង់** | ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី (ហត្ថលេខា)

**នរោត្តម សីហមុនី**

៣រស. ១៥០២. ១០៧

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០៤/១៥ ...... វ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
(ហត្ថលេខា និងត្រា)

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ហ៊ិង ចំនួម៉ុន្នា** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៣៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៣៣. ១៥០២. ១១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់លោកវរសេនីយ៍ឯក **ខឡុនៈ មង្គល** អត្តលេខ ៩៧៨៧២ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការស. ១៥០២. ១១១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ៦៤២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃ ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដី ខាងក្រោមស្ពានច្បារ ត្រង់ចន្លោះផ្លូវលេខ

១០៦ និងផ្លូវលេខ ១០៨ ក្នុងសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានទីតាំង Aទំហំ ២ ៨៩៨,១៩ ម៉ែត្រក្រឡា ទីតាំងB ទំហំ ២ ៦៨៤,៧៣ ម៉ែត្រក្រឡា និងទីតាំងC ទំហំ ៣ ០១៤,៤២ ម៉ែត្រក្រឡា តាមប្លង់ក្បាលដី ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ដែលរៀបចំដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ។

**មាត្រា ២.-**

ត្រូវបានចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដូចមានចែងក្នុងប្រការ១នៃអនុក្រឹត្យនេះ ស្របតាមលក្ខខណ្ឌដូចខាងក្រោម÷

-ត្រូវដំណើរការដាក់ជួល ស្របតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន

-ការអភិវឌ្ឍទីតាំងដូចមានចែងក្នុងប្រការ១ ត្រូវដំណើរការ ស្របតាមបទប្បញ្ញត្តិជាធរមាន

-ការជួលទ្រព្យសម្បត្តិរដ្ឋនេះ មិនត្រូវធ្វើឱ្យផ្លាស់ប្តូរមុខងារបម្រើសេវាសាធារណៈ នៃទ្រព្យសម្បត្តិដែលស្ថិតនៅទីតាំងផ្នែកខាងលើឡើយ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣ /១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងមហាផ្ទៃ
- តាមសំណើ របស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- តាមសំណើ របស់ក្រសួងយុត្តិធម៌
- តាមសំណើ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- តាមសំណើ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- តាមសំណើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដូចខាងក្រោម÷

- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ស្ថិតនៅឡូតិ៍លេខ ៦២ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានដីទំហំ ១.៨១៥ ម៉ែត្រក្រឡា។
- អតីតអគារ NiDA ស្ថិតនៅអគារ ១១៣ នៅកែងផ្លូវ២១៤ និងផ្លូវ១៨៣ និងអគារគ្មានលេខនៅកែងផ្លូវ២១៤ និងផ្លូវ១៨១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ មានដីទំហំ ១.៣២១,១៩ ម៉ែត្រក្រឡា។
- អគារសាលាដំបូង ខេត្តព្រះសីហនុ ស្ថិតនៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានដីទំហំ ១.២០៦ ម៉ែត្រក្រឡា។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ថិតនៅផ្លូវឯករាជ្យ ក្នុងភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានដីទំហំ ១.១៤០ ម៉ែត្រក្រឡា។
- សាលាសង្កាត់លេខ៤ចាស់ ខេត្តព្រះសីហនុ ស្ថិតនៅផ្លូវឯករាជ្យ ក្នុងភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានដីទំហំ ៥៩៨ ម៉ែត្រក្រឡា។
- អតីតសិប្បកម្មជីសរ ស្ថិតនៅផ្លូវលេខ៤៨៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មានដីទំហំ ៨៩២ ម៉ែត្រក្រឡា។
- មន្ទីរកសិកម្ម ខេត្តកំពង់ចាម ស្ថិតនៅភូមិ១១ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានដីទំហំ ១.៨៩៨ ម៉ែត្រក្រឡា និងឃ្លាំងកសិកម្ម ស្ថិតនៅផ្លូវព្រះសីហនុ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានដីទំហំ ៨៣៤ ម៉ែត្រក្រឡា។
- មន្ទីរកសិកម្ម ខេត្តស្វាយរៀង ស្ថិតនៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង មានដីទំហំ ២.៤១៣ ម៉ែត្រក្រឡា។
- ដីមួយកន្លែងរបស់ក្រុមហ៊ុន ហ្វ្រីនត្រេដ ក្រសួងពាណិជ្ជកម្ម ស្ថិតនៅភូមិសំណង់ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានទំហំដី ៣.៦៦២ ម៉ែត្រក្រឡា។
- ដីមន្ទីរពាណិជ្ជកម្មចាស់ ខេត្តព្រះសីហនុ ស្ថិតនៅភូមិ២ សង្កាត់លេខ២ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ មានទំហំដី ៣៨៦ ម៉ែត្រក្រឡា និងដីទល់មុខសណ្ឋាគារកោះរ៉ុង មានទំហំ ៥១៤ ម៉ែត្រក្រឡា។
- ដីមួយផ្នែកនៃមន្ទីរព័ត៌មាន ខេត្តកោះកុង ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ មានទំហំដី៣.៦០០ ម៉ែត្រក្រឡា។
- ដីមួយកន្លែងរបស់ក្រុមហ៊ុន ហ្វ្រីនត្រេដ ក្រសួងពាណិជ្ជកម្ម ស្ថិតនៅផ្លូវលេខ៣ ភូមិមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ដីមានទំហំ ៣១.១៦ ម៉ែត្រក្រឡា។

**មាត្រា២.-**

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធី ដោយក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងព័ត៌មាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងសាលារាជធានីភ្នំពេញ។

**មាត្រា ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួង-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអភិបាលសាលារាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៦៥អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.—**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន១១០ ០០០ ០០០រៀល (មួយរយដប់លានរៀលគត់) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**មាត្រា២.—**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ការចំណាយបុណ្យសពនាយទាហានថ្នាក់ឧត្តមសេនីយ៍ក្រសួងការពារជាតិចំនួន ០២រូប រួមមានឧត្តមសេនីយ៍ឯកចូលនិវត្ត ប៉ាន់ ថៃ និងឧត្តមសេនីយ៍ទោ យឹម ពីម។

**មាត្រា៣.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនិងឧបត្ថម្ភដល់ជនពិការ កុមារកំព្រា និងចាស់ជរាគ្មានទីពឹង រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅស្រុកកងមាស ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឧបាសក | **លន់ ផាន់** | ប្រធានអាចារ្យវត្តកងតាណឹង | |
| ២-ឧបាសក | **ច្រឹក ឡុញ** | អនុប្រធានអាចារ្យវត្តកងតាណឹង | |
| ៣-ឧបាសក | **មឿន ស៊ីម៉ន** | អនុប្រធានអាចារ្យវត្តកងតាណឹង | |
| ៤-ឧបាសក | **កខ កែម** | គណៈកម្មការវត្តកងតាណឹង | |
| ៥-ឧបាសក | **ឌូច អ៊ីម** | គណៈកម្មការវត្តកងតាណឹង | |
| ៦-លោក | **សំ សុភ័ក្ត្រ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៣៥.៥០០ ដុល្លារ |
| ៧-ឧបាសិកា | **ព្រុំ សុគន្ធ** | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកាចំនួន ៣៥.៥០០ ដុល្លារ |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** [illegible]

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

### សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនិងឧបត្ថម្ភដល់ជនពិការ កុមារកំព្រា និងចាស់ជរាគ្មានទីពឹង រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅស្រុកកងមាស ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-អ្នកស្រី | **ឆាយ រ៉ុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៣.០០០ ដុល្លារ |
| ២-អ្នកស្រី | **យូ សាខាម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៨០០ ដុល្លារ |
| ៣-អ្នកស្រី | **ឡូ គីមអេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៨០០ ដុល្លារ |
| ៤-អ្នកស្រី | **យូ ម៉ាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៦០០ ដុល្លារ |
| ៥-អ្នកស្រី | **ម៉ាន់ វណ្ណា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ៦-អ្នកស្រី | **ឈាង សុខហាង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៥០០ ដុល្លារ |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៥
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ឆាន់ ចន្ទសុគន្ធី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ពីប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ ឱ្យទៅកាន់មុខតំណែងជាប្រធាននាយកដ្ឋានរដ្ឋបាល សរុប នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។

**មាត្រា ២ :** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៤រូប ឱ្យកាន់មុខតំណែងជា អគ្គនាយករង និងប្រធាននាយកដ្ឋាន នៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោក **សួន តារា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអគ្គនាយករង

២-លោក **សួស ច្រាដ្ឋា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និង ខេត្ត

៣-លោក **ឈឹម ភាន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ

៤-លោក **មួន ហេង** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ជាប្រធាននាយកដ្ឋានមុខងារ និងធនធាន។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ថោង ស្រាន់** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១៤ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១០០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអន្លង់វែង

## សម្រេច

**ប្រការ១ .-**

ត្រូវបានបន្ថែមសមាសភាពនៃគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ស ថាវី** | អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | អនុប្រធាន |
| ២-ឯកឧត្តមឧត្តមសេនីយ៍ទោ **ឆួន នៅ** | មេបញ្ជាការរងយោធភូមិភាគទី៤<br>និងជាមេបញ្ជាការសមរភូមិទិសទី២ | អនុប្រធាន |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៩.ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ....០៥៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យទន្លេឆ្នាំ២០១៥ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥ នៅខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ស្តីពីពិធីបុណ្យទន្លេ
- យោងសេចក្តីជូនដំណឹងលេខ ១៦៨២ សជណ.ផក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យទន្លេ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥ នៅខេត្តក្រចេះ ក្រោមប្រធានបទ «ទេសចរណ៍តាមដងទន្លេសម្រាប់ការអភិវឌ្ឍសហគមន៍»

ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **សរ ចំរ៉ុង** | អភិបាលនៃគណៈអភិបាលខេត្តក្រចេះ | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ូ តិរិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម **សូ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥-ឯកឧត្តម **អ៊ុក សុជាតិ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៧- ឯកឧត្តម **ជា មូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៨- ឯកឧត្តម **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៩- ឯកឧត្តម **តែ គុយស៊ាង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០- ឯកឧត្តម **យិន គិមស៊ាន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១១- ឯកឧត្តម **លី ម៊ុនធឿន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២- ឯកឧត្តម **អ៊ិន ចន្ថា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣-ឯកឧត្តម **តន់ វ៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤-ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ១៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **ទូច ណារ៉ុថ** | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស | សមាជិក |
| ១៧- ឯកឧត្តមឧត្តមសេនីយ៍ឯក **ខត្យ ពិសេន** | មេបញ្ជាការរងនិងជានាយសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៨- ឯកឧត្តមឧត្តមសេនីយ៍ឯក **ពិន ពិសិដ្ឋ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេស្តន៍នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៩- ឯកឧត្តម **ប្រាជ្ញ ច័ន្ទ** | អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ២០- ឯកឧត្តម **លន់ លឹមថៃ** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | សមាជិក |
| ២១- ឯកឧត្តម **កុល សំអុល** | អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ២២- ឯកឧត្តម **ស្តើង សុខុម** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៣- ឯកឧត្តម **ឱក តារារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៤- ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៥- ឯកឧត្តម **ឡូន សុមេធ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៦- ឯកឧត្តម **វ៉ាត់ ចំរើន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៧- ឯកឧត្តម **តុប សុភ័ក** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៨- លោកជំទាវ **ហ៊ីន ដានី** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកា |
| ២៩- ឯកឧត្តម **ជា សៃ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៣០- ឯកឧត្តម **សូ ទិសុទ្ធី** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៣១- ឯកឧត្តម **ណូ សម្បុក** | អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ | សមាជិក |

| | | |
|---|---|---|
| ៣២- ឯកឧត្តម **ណោប សាមុត** | អគ្គនាយកទេសចរណ៍និងជាអគ្គលេខាធិការ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | សមាជិក |
| ៣៣- ឯកឧត្តម **គង់ សូលីដា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុក្រសួងទេសចរណ៍ | សមាជិក |
| ៣៤- លោក **ឯម យិនទីរៈ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៣៥- លោក **ហង់ ចាន់ឌី** | អភិបាលក្រុងក្រចេះ | សមាជិក |
| ៣៦- លោក **រុន តារ៉ា** | ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ | សមាជិក |
| ៣៧- លោក **ឈ្លាង សុខុន្ថា** | ប្រធានមន្ទីរសុខាភិបាលខេត្តក្រចេះ | សមាជិក |
| ៣៨- លោក **ណុប ចន្ធី** | ប្រធានមន្ទីរបរិស្ថានខេត្តក្រចេះ | សមាជិក |
| ៣៩- លោក **គុយ ហ្វួត** | ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ | សមាជិក |
| ៤០- លោក **ឡាយ មូរ៉ា** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ | សមាជិក |
| ៤១- លោក **ស្រេង ស្រស់** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ | សមាជិក |
| ៤២- លោក **សុខ គិរីរតន៍** | ប្រធានមន្ទីររ៉ែ និងថាមពលខេត្តក្រចេះ | សមាជិក |
| ៤៣- លោក **ឌី ឆុន** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តក្រចេះ | សមាជិក |
| ៤៤- លោក **ហេង រ័ត្នម៉ូនីដា** | ប្រធានមន្ទីរធនធានទឹកខេត្តក្រចេះ | សមាជិក |
| ៤៥- លោក **នូ ច័ន្ទតារា** | ប្រធានមន្ទីរធម្មការ និងសាសនាខេត្តក្រចេះ | សមាជិក |
| ៤៦- លោក **ទេព វាសនា** | ប្រធានស្តីទីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តក្រចេះ | សមាជិក |
| ៤៧-លោក **ថាច់ សុវណ្ណា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងនិងអភិរក្សធនធានទឹក ក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |

គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំពិធីបុណ្យទន្លេ ឆ្នាំ២០១៥ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥ នៅខេត្តក្រចេះ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

**ប្រការ២.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន និងអនុគណៈកម្មការរបស់គណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យទន្លេឆ្នាំ២០១៥ ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

**ក. លេខាធិការដ្ឋាន**

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា មូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **គង់ សូលីដា** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- លោក **ផ្លុង ធឿន** | អគ្គនាយករងនិងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- លោក **ជា កុសល** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ និងជា នាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥- លោក **នឹម សុវណ្ណា** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៦- លោក **ម៉ម វាសនា** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | អនុប្រធាន |

| | | |
|---|---|---|
| ៧- លោក **សុខ គុខហាប់** | ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៨- លោក **ជុក ជំនោរ** | ប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាននៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៩- លោក **គីម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០- លោក **ឆែន រតនា** | ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោក **គង់ សុភារក្ស** | ប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១២- លោក **ជា ចាន់ហេខ** | ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **សារុន វ៉ាឌី** | ប្រធាននាយកដ្ឋានផ្ទៃក្នុងនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤- លោក **រុន តារ៉ា** | ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ | សមាជិក |
| ១៥- លោក **ហេខ សុជាតី** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៦- លោក **ទឹខ មុន្នី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៧- លោក **ម៉ុយ សែ** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៨- លោក **ឆួន សេដា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៩- លោកស្រី **ឯម ថ៉ាន់សាន៉ារ័ត្ន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិកា |
| ២០- លោក **ភែម ឆា** | អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងទេសចរណ៍ | សមាជិក |
| ២១- លោក **សៅរ៍ ច័ន្ទពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២២- លោកស្រី **អៀខ សុខម៉េខ** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងទេសចរណ៍ | សមាជិកា |
| ២៣- លោក **ប៉ែន លីណាត** | នាយករដ្ឋបាលសាលាខេត្តក្រចេះ | សមាជិក |
| ២៤- លោក **ទន់ វណ្ណៈ** | នាយការិយាល័យ នៃក្រសួងទេសសចរណ៍ | សមាជិក |
| ២៥- លោក **លី ជីឃាខ** | នាយការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៦- លោកស្រី **សារិន ភញ្ញានា** | នាយការិយាល័យរដ្ឋបាល និងរបៀប នៃក្រសួងទេសចរណ៍ | សមាជិកា |
| ២៧- លោក **ប៉ែន សុវណ្ណា** | នាយការិយាល័យសរុប នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៨- លោកស្រី **នុប សុធនិទ្ទ្រ** | នាយការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិកា |

| | | |
|---|---|---|
| ២៩- លោកស្រី **យូ សុគន្ធារី** | នាយការិយាល័យពិធីការ នៃក្រសួងទេសចរណ៍ | សមាជិកា |
| ៣០- លោក **ម៉ិន សុស្សា** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៣១- លោក **ហេង សុធិល** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៣២- កញ្ញា **ទ្រី សុខឡា** | នាយរងការិយាល័យរដ្ឋបាល នៃក្រសួងទេសចរណ៍ | សមាជិកា |
| ៣៣- កញ្ញា **ខិន ផានិត** | នាយរងការិយាល័យពិធីការ នៃក្រសួងទេសចរណ៍ | សមាជិកា |
| ៣៤- លោក **តូច សុម៉ានី** | ជំនួយការឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៣៥- លោក **អៀង សុគុណា** | ជំនួយការឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

លេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាជំនួយដល់គណៈកម្មការអន្តរក្រសួងក្នុងការដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយក្រសួង ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំបច្ចេកទេសនានាសម្រាប់គណៈកម្មការអន្តរក្រសួង
- រៀបចំកម្មវិធីបើកពិធីបុណ្យទន្លេ
- រៀបចំវេទិកាគណៈអធិបតី កន្លែងអង្គុយ និងពិធីការសម្រាប់ឥស្សរជនជាតិ និងអន្តរជាតិ
- រៀបចំលិខិតអញ្ជើញភ្ញៀវជាតិ និងអន្តរជាតិ ចូលរួមពិធីបើកពិធីបុណ្យទន្លេ
- រៀបចំបញ្ជីឈ្មោះភ្ញៀវជាតិ និងអន្តរជាតិ ចូលរួមពិធីបើកពិធីបុណ្យទន្លេ
- រៀបចំស្លាកពាក់សម្រាប់ភ្ញៀវជាតិ-អន្តរជាតិ ចូលរួមពិធីបើកពិធីបុណ្យទន្លេ
- រៀបចំប័ណ្ណចតរថយន្តសម្រាប់ភ្ញៀវជាតិ-អន្តរជាតិ ចូលរួមពិធីបើក និងពិធីបុណ្យទន្លេ
- រៀបចំពិធីការ និងបដិសណ្ឋារកិច្ចទទួលគណៈប្រតិភូ និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- រៀបចំការស្នាក់នៅ ហូបចុក និងដឹកជញ្ជូន ជូនសមាជិកគណៈកម្មការ និងក្រុមការងារ
- ស្វែងរកជំនួយឧបត្ថម្ភជាសម្ភារៈ ឬថវិកាពីសប្បុរសជន និងផ្នែកឯកជន ដើម្បីទ្រទ្រង់ការរៀបចំពិធីបុណ្យទន្លេ
- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ ចំណូល ចំណាយ ដើម្បីបម្រើដល់ដំណើរការរៀបចំពិធីបុណ្យទន្លេ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលពិធីបុណ្យទន្លេជូនរាជរដ្ឋាភិបាល
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**ខ.អនុគណៈកម្មការផ្សព្វផ្សាយ តាំងពិព័រណ៍ មហោស្រពម្ហូបអាហារ និងតុបតែងលម្អក្នុងពិធីបុណ្យ**

| | | |
|---|---|---|
| ១- ឯកឧត្តម **សូ ម៉ារ៉ា** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **ជា បូរ៉ា** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តម **នួន សុមេធ** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម **សូ វិសុទ្ធី** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥- ឯកឧត្តម **ឈោប សាមុត** | អគ្គនាយកទេសចរណ៍ និងជាអគ្គលេខាធិការ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | អនុប្រធាន |
| ៦- ឯកឧត្តម **សុខ សទ្ធារ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិ វាយតម្លៃទីក្រុងស្អាត | អនុប្រធាន |
| ៧- លោកស្រី **មិន សុតី** | អភិបាលរងខេត្តក្រចេះ | អនុប្រធាន |

| | | |
|---|---|---|
| ៨- លោក **លូ ម៉េង** | ប្រធានសមាគមសណ្ឋាគារកម្ពុជា | អនុប្រធាន |
| ៩- លោក **ប្រាក់ ច័ន្ទតារា** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០- លោក **ទ្រី ឈីម** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោកស្រី **តឹក សុធី** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិកា |
| ១២- លោក **ម៉ែន មុន្នីវឌ្ឍនៈ** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **ឡោ ឆូរ៉ា** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និង ផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោក **សុខ សុគុណា** | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៥- លោក **គឹម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៦- លោក **កែន សុធី** | អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៧- លោក **ជួប សោភ័ណ** | អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៨- លោក **រុន តារ៉ា** | ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ | សមាជិក |
| ១៩- លោក **ហ៊ុល សីលា** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និង ផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២០- លោក **ឃិន ណាត** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២១- លោក **ថាច ម៉ិនថាន** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និង ផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២២- លោក **ប្រាក់ ឧទ្ធី** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និង ផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៣- លោក **ម៉ិន សុស្សា** | នាយរងការិយាល័យនៃក្រសួងទេសចរណ៍ | សមាជិក |
| ២៤- លោក **យក់ សារ៉ាយ** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |

**អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- សហការជាមួយបណ្តាញព័ត៌មានផ្សព្វផ្សាយ និងផ្នែកឯកជន ដើម្បីធ្វើការឃោសនាផ្សព្វផ្សាយពីព្រឹត្តិការណ៍បុណ្យទន្លេ
- រៀបចំការតាំងពិព័រណ៍ ផលិតផលតាមដងទន្លេ
- សហការជាមួយអាជ្ញាធរដែនដី សមាគមឧស្សាហកម្មទេសចរណ៍ ក្រុមហ៊ុនស្រាបៀរ ភេសជ្ជៈ និងម្ហូបអាហារ ដើម្បីរៀបចំមហោស្រពម្ហូបអាហារ ស្រា និងភេសជ្ជៈ
- រៀបចំតុបតែងកន្លែងប្រារព្ធពិធី និងសហការរៀបចំតុបតែងលម្អ និងសម្អាតក្រុងក្រចេះ និងរៀបចំការសម្អាតមាត់ទន្លេនៅខេត្តក្រចេះ ដើម្បីទទួលស្វាគមន៍ពិធីបុណ្យទន្លេ

- រៀបចំបាញ់កាំជ្រួចអបអរសាទរពិធីបុណ្យទន្លេ និងសហការរៀបចំផ្សព្វផ្សាយបន្តផ្ទាល់
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**គ. អនុគណៈកម្មការរៀបចំកីឡាលើទឹក និងកីឡាផ្សេងៗ**

| | | |
|---|---|---|
| ១- ឯកឧត្តម **ទ៉ាត់ ចំរើន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ | | អនុប្រធាន |
| ៣- ប្រធានសហព័ន្ធកីឡាជាតិពាក់ព័ន្ធ | | សមាជិក |

អនុគណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- រៀបចំសកម្មភាពកីឡាលើទឹក កីឡាលើឆ្នេរខ្សាច់ និងសកម្មភាពកីឡាផ្សេងៗទៀត ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនឯកជន និងប្រទេសជាមិត្តនានា
- ទទួលភារកិច្ចផ្សេងទៀត ដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**ឃ. អនុគណៈកម្មការរៀបចំខ្លឹមសារ និងពង្រឹងគុណភាពសេវាកម្ម និងការងារបរិស្ថាន និងអនាម័យ**

| | | |
|---|---|---|
| ១- ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **គុប សុភ័គ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- ឯកឧត្តម **ឈោម សាមុត** | អគ្គនាយកទេសចរណ៍ និងជាអគ្គលេខាធិការ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | អនុប្រធាន |
| ៤- ឯកឧត្តម **អាំង សុវណ្ណរ័ត្ន** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៥- លោក **ជា កុសល** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ៦- លោក **ទ្រី ឈឹម** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ៧- លោក **ហ៊ុយ គីរវៀ** | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ៨- លោក **ជុក ជំនោរ** | ប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងធម្មជាតិ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៩- លោក **ជុក សុខុម** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០- លោក **សុខ សុគុណា** | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោក**ឡោធូរ៉ា** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១២- លោក **ជួន ជ័យសត្យា** | ប្រធានក្រុមអ្នកច្បាប់ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **គីម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោក **យិន ណារា** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |

| | | |
|---|---|---|
| ១៥- លោក **លីវ ចណ្ណារោច** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៦- លោកស្រី **ហួត ស៊ីនួន** | អនុប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិកា |
| ១៧- លោក **មាន វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៨- លោក **ឈុន មករា** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៩- លោក **កែន សុភី** | អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ២០- លោក **ទិបុល អតិវឌ្ឍន៍** | អនុប្រធាននាយកដ្ឋានស្ថិត និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២១- លោក **ជា ធីរៈ** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២២- លោក **ខ្មៅ កុសល** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៣- លោក **ឡាច តិកុល** | ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ២៤- លោក **មាន ប៉ុណ្ណា** | ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ២៥- លោក **ផយ មធុរៈ** | មន្ត្រីនាយកដ្ឋានទេសចរណ៍វប្បធម៌និងរមណីយដ្ឋាន | សមាជិក |
| ២៦- កញ្ញា **រ៉ុម ច័ន្ទបូរី** | មន្ត្រីនាយកដ្ឋានទេសចរណ៍វប្បធម៌និងរមណីយដ្ឋាន | សមាជិកា |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោមៈ
- រៀបចំសុន្ទរកថាជូនថ្នាក់ដឹកនាំសម្រាប់កម្មវិធីបើកពិធីបុណ្យទន្លេ
- រៀបចំខ្លឹមសារឯកសារពាក់ព័ន្ធនានាសម្រាប់ដំណើរការរៀបចំពិធីបុណ្យទាំងមូល
- រៀបចំបកប្រែ និងបោះពុម្ពឯកសារសំខាន់ៗ
- សហការជាមួយអាជ្ញាធរខេត្តក្រចេះ រៀបចំកម្មវិធីសម្អាតក្រុង មុន និងក្រោយពិធីបុណ្យ
- ចុះរៀបចំសហគមន៍ទេសចរណ៍ និងពង្រឹងគុណភាពផលិតផលក្នុងតំបន់ (ក្រូចឆ្មារ ក្រឡាន វត្តអនុស្សាវរីយ៍...)
- ចុះពង្រឹងគុណភាពសេវាកម្ម និងការបញ្ជ្រាបការដឹងជាសាធារណៈ មុនពិធីបុណ្យ
- ជំរុញយុទ្ធនាការចលនាការប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ នៅតាមរមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ សេវាទេសចរណ៍គ្រប់ប្រភេទ ដោយរៀបចំឱ្យមានការជូនរង្វាន់ជាបណ្ណសរសើរ ឬការលើកទឹកចិត្តដល់ប្រតិបត្តិករ និងបុគ្គលដែលមានស្នាដៃ
- ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**ខ.អនុគណៈកម្មការរៀបចំទស្សនីយភាពសិល្បៈ**

| | | |
|---|---|---|
| ១- ឯកឧត្តម **ប៉ាក់ សុខុម** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **អ៊ុក សុជាតិ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- លោក **ព្រឿង ឈាង** | ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៤- លោក **ហ៊ឹម សុភា** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |

| | | |
|---|---|---|
| ៥- លោក **ហេង សុខចំរើន** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ និងជានាយករងខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងទេសចរណ៍ | សមាជិក |
| ៦- លោក **ឃិន ស៊ីផេង** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៧- លោក **ឡោ ធូរ៉ា** | ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៨- លោក **ម៉ៅ កេង** | ប្រធាននាយកដ្ឋានទស្សនីយភាពសិល្បៈ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៩- លោក **ងឹង មុន្នី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០- លោក **កែន សុតី** | អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោក **នង មុន្នីកា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១២- លោក **ស្រ៊ន សុវណ្ណារ៉ា** | អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **សុខ ស៊ីណារិទ្ធ** | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោក **នុត នារត្ន** | អនុប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៥- លោកស្រី **សៀង ទៀង** | នាយិកាសាលាមធ្យមវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌និង វិចិត្រសិល្បៈ | សមាជិកា |
| ១៦- លោក **គីម ធីរៈ** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៧- លោក **ម៉ៅ ធីរៈ** | នាយរងការិយាល័យ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៨- លោក **សិដ្ឋ ចាន់ធារិទ្ធ** | មន្ត្រីនាយកដ្ឋានទេសចរណ៍វប្បធម៌និងរមណីយដ្ឋាន | សមាជិក |
| ១៩- លោក **សាត ធារិទ្ធ** | មន្ត្រីនាយកដ្ឋានទេសចរណ៍វប្បធប៌និងរមណីយដ្ឋាន | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សហការជាមួយអនុគណៈកម្មការនានា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំទស្សនីយភាពសិល្បៈ សម្រាប់ពិធីបើក ការប្រគុំតន្ត្រី កម្មវិធីសិល្បៈកម្សាន្តនានា និងព្យុះហយាត្រាក្នុងឱកាសពិធីបុណ្យទន្លេ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**ច. អនុគណៈកម្មការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់**

| | | |
|---|---|---|
| ១- ឯកឧត្តមឧត្តមសេនីយ៍ឯក **ទូច ណារ៉ុថ** | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស | ប្រធាន |
| ២- ឯកឧត្តមឧត្តមសេនីយ៍ឯក **ខេង្យ ពិសេន** | មេបញ្ជាការរង និងជានាយសេនាធិការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣- លោក **ហឿ ស៊ីយ៉េម** | អភិបាលរងខេត្តក្រចេះ | អនុប្រធាន |
| ៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **ញាណា វិបុល** | ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ | សមាជិក |

| | | |
|---|---|---|
| ៥- លោក **ប្រាក់ ច័ន្ទតារា** | អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ៦- ឧត្តមសេនីយ៍ត្រី **លន់ សុផាត** | ស្នងការនគរបាលខេត្តក្រចេះ | សមាជិក |
| ៧- ឧត្តមសេនីយ៍ត្រី **កែវ ជា** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តក្រចេះ | សមាជិក |
| ៨- ឧត្តមសេនីយ៍ត្រី **ណៃ តឹខឡឹខ** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តក្រចេះ | សមាជិក |
| ៩- លោក **ឡោ សុវិជ្ជា** | អធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០- លោក **សាន់ សារី** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល | សមាជិក |
| ១១- លោក **នុន តារ៉ា** | ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ | សមាជិក |
| ១២- លោក **ឈ្លាខ សុខុន្តា** | ប្រធានមន្ទីរសុខាភិបាលខេត្តក្រចេះ | សមាជិក |
| ១៣- លោក **សំ ខុន្ធា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ | សមាជិក |

**អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- រៀបចំការពារសន្តិសុខ សុវត្ថិភាព របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងចរាចរណ៍ឱ្យជានាបាននូវសុវត្ថិភាព គ្រប់គ្រាន់ទាំងមុនពេល ក្នុងពេល និងក្រោយពេលនៃការប្រារព្ធពិធីបុណ្យទន្លេ
- ពិភាក្សា និងសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋកម្ពុជា-ថៃ-ឡាវ-វៀតណាម តាមច្រកទ្វារព្រំដែន នៅពេលបុណ្យទន្លេ
- ត្រៀមលក្ខណៈ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់សង្គ្រោះបន្ទាន់ ក្នុងករណីមានបាតុភាពជាយថាហេតុ ក្នុងពេលនៃការប្រារព្ធពិធីបុណ្យទន្លេ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន។

**ប្រការ៣.-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមតាមការចាំបាច់។ អនុគណៈកម្មការនីមួយៗនិងលេខាធិការដ្ឋាន អាចស្នើសុំជ្រើសរើសសមាជិកបន្ថែមតាមការចាំបាច់ដោយមានការយល់ព្រមពីប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤.-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ថវិការបស់ក្រសួងទេសចរណ៍ និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ និងឧបត្ថម្ភដល់ដំណើរការរៀបចំពិធីបុណ្យទន្លេនេះ។

**ប្រការ៥.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

អនុប្រធាន សមាជិកគណៈកម្មការ ប្រធាន អនុប្រធាន សមាជិកអនុគណៈកម្មការ និងលេខាធិការដ្ឋានត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៦.-**

គណៈកម្មការអន្តរក្រសួងនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥១......សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៥

# ប្រកាស
# ស្តីពី
# ការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរឥណទានថវិកាជំពូក៦៤ (ប្រាក់បៀវត្ស) ជូនប្រធានមន្ទីរ ឬអង្គភាព នៅតាមរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០២សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមគណនីនិងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញសារាចរបស់រាជរដ្ឋាភិបាលលេខ ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

**សម្រេច**

**ប្រការ១.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ដែលជាអាណាប័កដើមខ្សែ ត្រូវរៀបចំប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកាជំពូក ៦៤ (ប្រាក់បៀវត្ស) ជូនប្រធានមន្ទីរ ឬអង្គភាពនៅតាមរាជធានី ខេត្ត ឱ្យបានទាន់ពេលវេលា ស្របតាមខ្លឹមសារនៃសារាចរបស់រាជរដ្ឋាភិបាលលេខ ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល។ ឥណទានថវិកាក្រៅពីជំពូក៦៤ (ប្រាក់បៀវត្ស) គឺនៅរក្សាការអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ១៩០២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ដដែល។

**ប្រការ២.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលនៃគណៈអភិបាលគ្រប់រាជធានី ខេត្ត ប្រធានមន្ទីរ ឬអង្គភាពគ្រប់រាជធានី ខេត្ត ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

**ប្រការ៣.-**

ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់រាជធានី ខេត្ត
- គ្រប់មន្ទីរ អង្គភាព នៅតាមរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខ ១៧៨ សហវ.ប្រក

# ប្រកាស

## ស្តីពី

## គោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្ម
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤២ សសរ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ
- បានឃើញប្រកាសលេខ ១០៨១ សហវ.ប្រក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងការផ្តល់ឥណទាន។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់គោលការណ៍និងនីតិវិធីនៃការផ្តល់ឥណទាន ការគ្រប់គ្រងការផ្តល់ឥណទាន សិទ្ធិនិងកាតព្វកិច្ចរបស់ឥណទាយិក និងយន្តការដោះស្រាយវិវាទពាក់ព័ន្ធការផ្តល់ឥណទាន។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់ឥណទាននៅក្នុងប្រទេស ដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ដោយអនុលោមតាមមាត្រា២២ នៃអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

ប្រកាសនេះ មិនមានវិសាលភាពគ្របដណ្តប់លើប្រតិបត្តិការនៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍវិស័យកសិកម្មទេ។

**ប្រការ៤.-**

និយមន័យនៃវាក្យស័ព្ទនៃប្រកាសនេះ ត្រូវបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

## ជំពូកទី២

## គោលការណ៍ លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ឥណទាន

**ប្រការ៥.-**

ការផ្តល់ឥណទាន ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម÷

- សម្រាប់ហិរញ្ញប្បទានលើកម្មវិធី ឬគម្រោង ក្នុងកម្មវិធីវិនិយោគសាធារណៈដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ វិស័យអាទិភាពផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬតាមការសម្រេចជាយថាហេតុរបស់នាយករដ្ឋមន្ត្រី
- សម្រាប់ហិរញ្ញប្បទានលើកម្មវិធី ឬគម្រោង ដែលត្រូវបានវាយតម្លៃហានិភ័យរួចរាល់
- ទំហំឥណទាន ត្រូវស្ថិតក្នុងកម្រិតកំណត់របស់ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ត្រូវគិតការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀត។

**ប្រការ៦.-**

សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ ឬនីតិបុគ្គលសាធារណៈដទៃទៀត ដែលស្នើសុំឥណទានពីរដ្ឋ ត្រូវរៀបចំឯកសារស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រសួងអាណាព្យាបាលបច្ចេកទេស។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្នើសុំឥណទានពីរដ្ឋ ត្រូវរៀបចំឯកសារស្នើសុំដោយផ្ទាល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបានឯកសារស្នើសុំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិគ្រោះយោបល់ជាមួយធនាគារជាតិនៃកម្ពុជា។

សំណើសុំឥណទានពីរដ្ឋ ត្រូវមានឯកសារ និងព័ត៌មាន ដូចខាងក្រោម÷

- លិខិតស្នើសុំឥណទានពីរដ្ឋជាលាយលក្ខណ៍អក្សរ
- លិខិតបទដ្ឋានគតិយុត្តបង្កើតសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬអាជ្ញាប័ណ្ណអាជីវកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- លក្ខន្តិកៈរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យក្នុងការិយបរិច្ឆេទ ០៣(បី) ឆ្នាំចុងក្រោយ។
- ផែនការអាជីវកម្ម ដែលត្រូវមានព័ត៌មានចាំបាច់មួយចំនួន រួមមាន÷ ការសិក្សាសមិទ្ធលទ្ធភាពនៃកម្មវិធី ឬគម្រោងប្រភពទុនវិនិយោគ និងលទ្ធភាពសង
- ឯកសារនិងព័ត៌មានផ្សេងទៀត តាមការចាំបាច់។

**ប្រការ៧.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារស្នើសុំឥណទានដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីពិនិត្យនិងអនុម័ត ឬរៀបចំរបាយការណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីសុំការអនុម័ត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ៨.-**

លក្ខខណ្ឌឥណទាននីមួយៗ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អត្រាការប្រាក់ដែលត្រូវគិតពីឥណទាយិក ត្រូវផ្អែកតាមគោលការណ៍ ដូចខាងក្រោម÷

- ក្នុងករណីផ្តល់ឥណទានដោយប្រើថវិការដ្ឋ÷ ត្រូវយកអត្រាការប្រាក់ខ្ពស់បំផុតដែលរដ្ឋខ្ចីពីគេចុងក្រោយ បូកបន្ថែម កម្រិតហានិភ័យរូបិយប័ណ្ណ និងកម្រិតហានិភ័យឥណទាន ទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងកម្រៃសេវា ចំនួន ០,១៥% និងផលប្រយោជន៍ថវិកាជាតិ ក្នុងចន្លោះពី ០,៥០% ដល់ ១,៥០%។
- ក្នុងករណីផ្តល់ឥណទានដោយប្រើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍÷ ត្រូវយកអត្រាការប្រាក់នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បូកបន្ថែម កម្រិតហានិភ័យរូបិយប័ណ្ណ និងកម្រិតហានិភ័យឥណទាន ទៅតាមស្ថានភាពជាក់ស្តែង, កម្រិតហានិភ័យឥណប្រតិទាន ដែលមានអត្រាអប្បបរមា ០,២៥% ព្រមទាំងកម្រៃសេវាចំនួន ០,១៥% និងផលប្រយោជន៍ថវិកាជាតិ ក្នុងចន្លោះពី ០,៥០% ដល់ ១,៥០%។

**ប្រការ៩.-**

អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន និងឯកសារពាក់ព័ន្ធផ្សេងទៀត ព្រមទាំងដឹកនាំការចរចាជាមួយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីតំណាងក្រសួងអាណាព្យាបាលបច្ចេកទេស ឬធនាគារជាតិនៃកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ប្រការ១០.-**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងស្ថិតក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន ជាមួយតំណាងស្របច្បាប់របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មសិទ្ធិចុះហត្ថលេខានេះ តាមលិខិតជាលាយលក្ខណ៍អក្សរ បន្ទាប់ពីមានការអនុញ្ញាតពីនាយករដ្ឋមន្ត្រី។

## ជំពូកទី៣

## ការគ្រប់គ្រងការផ្តល់ឥណទាន

**ប្រការ១១.-**

អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការគ្រប់គ្រងការផ្តល់ឥណទាន ដោយមានភារកិច្ច ដូចតទៅ÷

- គ្រោងឥណទានថវិកាសម្រាប់ការផ្តល់ឥណទាន និងឥណទានថវិកាត្រៀមបម្រុង ដោយគោរពតាមប្រតិទិននៃការរៀបចំថវិកា ដូចមានចែងក្នុងមាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- កត់ត្រារាល់ប្រតិបត្តិការនៃការផ្តល់ឥណទាន
- គ្រប់គ្រង និងរក្សាទុករាល់កិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន និងឯកសារពាក់ព័ន្ធ
- តាមដាន និងត្រួតពិនិត្យទំហំឥណទានសរុបដែលរដ្ឋបានចុះកិច្ចព្រមព្រៀងផ្តល់ឥណទានក្នុងឆ្នាំនីមួយៗ និងទំហំឥណទានសរុបដែលគេនៅជំពាក់ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងទំហំឥណទានទាំងនោះឱ្យស្ថិតក្នុងកម្រិតកំណត់របស់ច្បាប់ ហិរញ្ញវត្ថុប្រចាំឆ្នាំ ព្រមទាំងស្ថិតក្នុងកម្រិតសមស្របដែលស្ថានភាពថវិកានិងសេដ្ឋកិច្ចជាតិអាចទ្រាំទ្របាន
- តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធី ឬគម្រោងវិនិយោគដែលទទួលបានឥណទានពីរដ្ឋ ដែលអនុវត្ត

ដោយសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

- ពិនិត្យ និងលើកសំណើដំណោះស្រាយ ចំពោះបញ្ហានានាពាក់ព័ន្ធការអនុវត្តកិច្ចព្រមព្រៀងស្ដីពីការផ្ដល់ឥណទានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសម្រេច ជាពិសេសក្នុងករណីដែលមានសញ្ញាណាមួយបង្ហាញថា សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តកម្មវិធី ឬគម្រោងវិនិយោគ ដោយមិនស្របតាមកិច្ចព្រមព្រៀងស្ដីពីការផ្ដល់ឥណទាន។

**ប្រការ១២.-**

ទម្រង់នៃរបាយការណ៍ស្ដីពីលទ្ធផលនៃការវាយតម្លៃសំណើកម្មវិធី ឬគម្រោងវិនិយោគ, ទម្រង់ព័ត៌មានស្ដីពីការផ្ដល់ឥណទាន, ទម្រង់នៃរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ឬគម្រោងប្រចាំត្រីមាស និងគំរូកិច្ចព្រមព្រៀងស្ដីពីការផ្ដល់ឥណទាន ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## សិទ្ធិនិងកាតព្វកិច្ចរបស់ឥណទាយិក

**ប្រការ១៣.-**

ឥណទាយិកមានកាតព្វកិច្ចទូទាត់សេវាបំណុលជូនរដ្ឋ តាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងស្ដីពីការផ្ដល់ឥណទាន។

ក្នុងករណីឥណទាយិកមិនបានទូទាត់សេវាបំណុលជូនរដ្ឋតាមកាលវសាន ឥណទាយិកត្រូវទទួលរងពិន័យ ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្ដីពីការផ្ដល់ឥណទាន។

**ប្រការ១៤.-**

ឥណទាយិកត្រូវផ្ដល់ជូន អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍ ដូចខាងក្រោម÷

- របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ឬគម្រោងប្រចាំត្រីមាស ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីដំណាច់ឆ្នាំថវិកា
- របាយការណ៍ពាក់ព័ន្ធផ្សេងទៀត តាមការតម្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៥.-**

ការផ្ទេរឥណទានពីឥណទាយិកទៅឱ្យអនុប្បទានិក ពុំត្រូវបានអនុញ្ញាតឡើយ។

**ប្រការ១៦.-**

រាល់ការស្នើសុំកែប្រែលក្ខខណ្ឌឥណទាន ត្រូវធ្វើឱ្យបានមុនពេលផុតកំណត់នៃឥណប្រតិទាន។

## ជំពូកទី៥
## ការដោះស្រាយវិវាទ

**ប្រការ១៧.-**

វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន ត្រូវដោះស្រាយក្នុងក្របខ័ណ្ឌនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើនិងអនុសាសន៍លើដំណោះស្រាយរបស់លេខាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម។

វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន សំដៅដល់វិវាទដែលកើតចេញពីការបង្កើត ការបកស្រាយ ការអនុវត្ត ការកែប្រែ ឬ ការរំលត់កាតព្វកិច្ចនៃកិច្ចព្រមព្រៀងនេះ។

**ប្រការ១៨.-**

ឥណទាយិកដែលមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិប្តឹងអំពីសេចក្តីសម្រេចនេះ ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីការពារសេចក្តីសម្រេចលើវិវាទដែលកើតចេញពីកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន នៅចំពោះមុខស្ថាប័នតុលាការ ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាពពីអគ្គនាយកដ្ឋានថវិកា លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងអគ្គនាយកដ្ឋានពាក់ព័ន្ធ តាមសំណើរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ - សទ្ទានុក្រម

**********

**កាលវាទសាន** (Due Date) សំដៅដល់កាលបរិច្ឆេទកំណត់ក្នុងការទូទាត់សេវាបំណុល។

**ការសិក្សាសមិទ្ធលទ្ធភាព** (Feasibility Study) សំដៅដល់ការវិភាគ និងការវាយតម្លៃទៅលើសំណើកម្មវិធី ឬគម្រោង ដោយពិនិត្យទៅលើកត្តានានាជាអាទិ៍÷ ទិដ្ឋភាពច្បាប់, លក្ខណៈបច្ចេកទេស, ស្ថានភាពហិរញ្ញវត្ថុ, និងផលចំណេញផ្ទៃក្នុងសេដ្ឋកិច្ច។

**ការផ្តល់ឥណទាន** (Lending and On-lending) សំដៅដល់ការឱ្យប្រាក់ដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខ្ចី ដោយប្រើថវិការដ្ឋ ឬហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្នុងគោលបំណងជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច- សង្គម។

**គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** (Banking and Financial Institutions) សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតក្រោមវិសាលភាពនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

**ប្រភពទុនវិនិយោគ** (Capital Sources) សំដៅដល់ដើមទុន និងបំណុល។

**សហគ្រាសសាធារណៈ** (Public Enterprise) សំដៅដល់សហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិនិងការបង្កើតអាជីព។

**សេវាបំណុល** (Debt Service) សំដៅដល់ការទូទាត់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀតនៃកាតព្វកិច្ចបំណុល។

**ហានិភ័យរូបិយប័ណ្ណ** (Currency Risk) សំដៅដល់ហានិភ័យដែលកើតឡើងដោយសារបម្រែបម្រួលអត្រាប្តូរប្រាក់រវាងរូបិយវត្ថុជាតិនិងរូបិយប័ណ្ណបំណុល ឬរវាងដុល្លារអាមេរិកនិងរូបិយប័ណ្ណបំណុល (ក្នុងបរិការណ៍នៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន) ហើយដែលធ្វើឱ្យប៉ះពាល់ដល់ទំហំនៃបន្ទុកសេវាបំណុល។

**ហានិភ័យឥណទាន** (Credit Risk) សំដៅដល់ហានិភ័យដែលកើតឡើងដោយសារឥណទាយិកខកខាន ឬមិនមានលទ្ធភាពក្នុងការទូទាត់សេវាបំណុល។

**អនុប្បទានិក** (Transferee) សំដៅដល់នីតិបុគ្គលដែលទទួលសិទ្ធិ និងកាតព្វកិច្ចបន្តពីឥណទាយិកដែលជាភាគីនៃកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន។

**ឥណទាយិក** (Debtor) សំដៅដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល នីតិបុគ្គលសាធារណៈដទៃទៀត ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានឥណទានពីរដ្ឋ។

**ឥណប្រតិទាន** (Maturity) សំដៅដល់រយៈពេលត្រូវសងបំណុលសរុប ដោយគិតចាប់ពីពេលដែលកិច្ចព្រមព្រៀងបំណុល កិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន ចូលជាធរមាន រហូតដល់បំណុលត្រូវបានសងអស់។ ឥណប្រតិទានស្មើនឹងរយៈពេលអនុគ្រោះ បូកនឹងរយៈពេលសងប្រាក់ដើម។